# កោសិយជាតក



*កោសិយជាតកនេះនឹងមានដាក់ច្បាស់* ***សុធាភោជនជាតក*** *(សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក អសីតនិបាត បិដកលេខ ៦១ ទំព័រ ១៣១) ឯណោះ ។*

*(ខាងក្រោមនេះជាសេចក្តីដែលមានមកក្នុងព្រះបាលី)៖*

**(កោសិយសេដ្ឋីពោលថា)**

**នេវ កិណាមិ នបិ វិក្កិណាមិ, ន ចាបិ មេ សន្និចយោ ច អត្ថិ;**
**សុកិច្ឆរូបំ វតិទំ បរិត្តំ, បត្ថោទនោ នាលមយំ ទុវិន្នំ ។**

*ខ្ញុំមិនទិញ មិនលក់ទេ ម្យ៉ាងទៀតការសន្សំ (នូវទ្រព្យ) របស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ បាយនេះតិច មានសភាពក្រក្រៃពេក បាយអង្ករ ១ កម្បង់នេះ មិនល្មមដល់ជនពីរនាក់ទេ ។*

(សក្កទេវរាជ ពោលថា)

អប្បម្ហា អប្បកំ ទជ្ជា, អនុមជ្ឈតោ មជ្ឈកំ;
ពហុម្ហា ពហុកំ ទជ្ជា, អទានំ នុបបជ្ជតិ ។

*បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គប្បីឲ្យវត្ថុពាក់កណ្តាល អំពីវត្ថុពាក់កណ្តាល គប្បីឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ ។*

តំ តំ វទាមិ កោសិយ, ទេហិ ទានានិ កុញ្ច ច ។
អរិយមគ្គំ សមារូហ, នេកាសី លភតេ សុខំ ។

*ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។*

(ចន្ទទេវបុត្រ ពោលថា)

មោឃញ្ចស្ស ហុតំ ហោតិ, មោឃញ្ចាបិ សមីហិតំ;
អតិថិស្មឹ យោ និសិន្នស្មឹ, ឯកោ ភុញ្ជតិ ភោជនំ ។

*បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា ឥតអំពើផង ការព្យាយាមញុំាងទ្រព្យឲ្យកើតរបស់បុគ្គលនោះ ឈ្មោះថា ឥតអំពើផង ។*

តំ តំ វទាមិ កោសិយ, ទេហិ ទានានិ កុញ្ច ច;
អរិយមគ្គំ សមារូហ, នេកាសី លភតេ សុខំ ។

*ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។*

(សុរិយទេវបុត្រ ពោលថា)

សច្ចញ្ចស្ស ហុតំ ហោតិ, សច្ចញ្ចាបិ សមីហិតំ;
អតិថិស្មឹ យោ និសិន្នស្មឹ, នេកោ ភុញ្ជតិ ភោជនំ ។

*បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ការព្យាយាមញុំាងទ្រព្យឲ្យកើត របស់បុគ្គលនោះថា ឈ្មោះថា សច្ចៈផង ។*

តំ តំ វទាមិ កោសិយ, ទេហិ ទានានិ ភុញ្ជ ច;
អរិយមគ្គំ សមារូហ, នេកាសី លភតេ សុខំ ។

*ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។*

(មាតលិទេវបុត្រ ពោលថា)

សរញ្ច ជុហាតិ ចោសោ, ពហុកាយ គយាយ ច;
ទោណេ តិម្ពរុតិត្ថស្មឹ, សីឃសោតេ មហាវហេ ។

*បុរស (ចូលទៅរក) ស្រះហើយបូជាក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់ឈ្មោះទោណៈផង ក្នុងកំពង់ឈ្មោះតិម្ពរុផង ក្នុងស្ទឹងធំមានខ្សែទឹកដ៏រហ័សផង ។*

អត្រ ចស្ស ហុតំ ហោតិ, អត្រ ចស្ស សមីហិតំ;
អតិថិស្មឹ យោ និសិន្នស្មឹ, នេកោ ភុញ្ជតិ ភោជនំ ។

*បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ការព្យាយាមញុំាងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ។*

តំ តំ វទាមិ កោសិយ, ទេហិ ទានានិ ភុញ្ជ ច;
អរិយមគ្គំ សមារុហ, នេកាសី លភតេ សុខំ ។

*ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។*

(បញ្ចសិខទេវបុត្រ ពោលថា)

ពឡិសញ្ហិ សោ និគិលតិ, ទីឃសុត្តំ សពន្ធនំ;
អតិថិស្មឹ យោ និសិន្នស្មឹ, ឯកោ ភុញ្ជតិ ភោជនំ ។

*បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង បុគ្គលនោះ ឈ្មោះថា លេបនូវសន្ទូចមានខ្សែវែង ព្រមទាំងរនង ។*

តំ តំ វទាមិ កោសិយ, ទេហិ ទានានិ ភុញ្ជ ច;
អរិយមគ្គំ សមារុហ, នេកាសី លភតេ សុខំ ។

*ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។*

(កោសិយសេដ្ឋីពោលថា)

ឧឡារវណ្ណា វត ព្រាហ្មណា ឥមេ, អយញ្ច វោ សុនខោ កិស្ស ហេតុ;
ឧច្ចាវចំ វណ្ណនិភំ វិកុព្វតិ, អក្ខាថ នោ ព្រាហ្មណា កោ នុ តុម្ហេ ។

*ឱហ្ន៎ ព្រាហ្មណ៍ទាំងនេះ មានវណ្ណៈដ៏លើសលុប ទាំងឆ្កែរបស់ពួកគាត់នេះ ក៏បញ្ចេញនូវពន្លឺនៃវណ្ណៈផ្សេង ៗ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់ដល់យើងចុះ តើពួកអ្នកជាអ្វី ។*

(សក្កទេវរាជពោលថា)

ចន្ទោ ច សុរិយោ ច ឧភោ ឥធាគតា, អយំ បន មាតលិ ទេវសារថិ;
សក្កោហមស្មិ តិទសានមិន្ទោ, ឯសោ ច ខោ បញ្ចសិខោតិ វុច្ចតិ ។

*ទេវបុត្រទាំងពីរអង្គ គឺចន្ទទេវបុត្រ ១ សុរិយទេវបុត្រ ១ មកក្នុងទីនេះ ឯទេវបុត្រនេះ ឈ្មោះមាតលិ ជាសារថីរបស់ទេវតា យើងឈ្មោះសក្កៈ ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ឯទេវបុត្រនេះ គេហៅថា បញ្ចសិខៈ ។*

ចាណិស្សរា មុទិង្គា ច, មុរជាលម្ពរានិ ច;
សុត្តមេនំ បពោធេន្តិ, បដិពុទ្ធោ ច នន្ទតិ ។

*សំឡេងទះដៃទាំងឡាយផង សម្ភោរតូចទាំងឡាយផង សម្ភោរធំ និងស្គរធំទាំងឡាយផង រមែងញុំាងបញ្ចសិខទេវបុត្រនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើង ឯបញ្ចសិខទេវបុត្រនេះ លុះភ្ញាក់ហើយក៏ត្រេកអរ ។*

យេ កេចិមេ មច្ឆរិនោ កទរិយា, បរិភាសកា សមណព្រាហ្មណានំ;
ឥធេវ និក្ខិប្ប សរីរទេហំ, កាយស្ស ភេទា និរយំ វជន្តិ ។

ពួកជនណានីមួយ ជាអ្នកកំណាញ់ស្អិតស្អាញ ប្រទេចផ្តាសានូវសមណៈ និងព្រាហ្មណ៍ទាំងឡាយ លុះទម្លាក់ចោលនូវរាងកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់នរក ។

យេ កេចិមេ សុគ្គតិមាសមានា, ធម្មេ ឋិតា សំយមេ សំវិភាគេ;
ឥធេវ និក្ខិប្ប សរីរទេហំ, កាយស្ស ភេទា សុគតឹ វជន្តិ ។

ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ ក្នុងសេចក្តីសង្រួម ក្នុងការចែករំលែក លុះទម្លាក់ចោលរាងកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់សុគតិ ។

ត្វំ នោសិ ញាតិ បុរិមាសុ ជាតិសុ, សោ មច្ឆរី រោសកោ បាបធម្មោ;
តវេវ អត្ថាយ ឥធាគតម្ហា, មា បាបធម្មោ និរយំ គមិត្ថ ។

អ្នកជាញាតិ របស់ពួកយើងក្នុងជាតិមុន អ្នកនោះ ឈ្មោះកោសិយៈ ជាអ្នកមានសេចក្តីកំណាញ់ មានធម៌ដ៏លាមក ពួកយើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ ដល់អ្នក (ដោយគិតថា) កុំឲ្យអ្នកមានធម៌ដ៏លាមក ទៅកាន់នរកឡើយ ។

(កោសិយសេដ្ឋីពោលថា)

អទ្ធា ហិ មំ វោ ហិតកាមា, យំ មំ សមនុសាសថ;
សោហំ តថា ករិស្សាមិ, សព្វំ វុត្តំ ហិតេសិភិ ។

ពួកលោកឈ្មោះថា ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយ ពិត ព្រោះពួកលោកបានប្រៀនប្រដៅខ្ញុំ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលពួកលោកជាអ្នកប្រាថ្នានូវប្រយោជន៍ បានពោល (រំលឹក) ហើយ ដោយបការៈដូច្នោះ ។

ឯសាហមេត្ថ ឧទារមាមិ, ន ចាបិហំ កិញ្ចិ ករេយ្យ ចាបំ;
ន ចាបិ មេ កិញ្ចិ អទេយ្យមត្ថិ, ន ចាបិទត្វា ឧទកំ បិវាមិ ។

*ខ្ញុំនេះនឹងវៀរលែង (ចាកសេចក្ដីកំណាញ់) នេះឯង ខ្ញុំនឹងឈប់ធ្វើបាបតិចតួចហើយ ទាំងវត្ថុតិចតួចដែលខ្ញុំមិនគប្បីឲ្យ មិនមាន ខ្ញុំបើមិនបានឲ្យទាន ទឹកនឹងមិនផឹកឡើយ ។*

ឯវញ្ច មេ ទទតោ សព្ពកាលំ, ភោគា ឥមេ វាសវ ខីយិស្សន្តិ;
តតោ អហំ បព្ពជិស្សាមិ សក្ក, ហិត្វាន កាមានិ យថោធិកានិ ។

*បពិត្រវាសវៈ កាលបើខ្ញុំឲ្យទាន អស់កាលទាំងពួងយ៉ាងនេះ ភោគៈទាំងឡាយ ក្នុងទីនេះនឹងអស់ទៅ បពិត្រសក្កៈ តពីនោះទៅ ខ្ញុំនឹងលះបង់កាមទាំងឡាយ តាមសមគួរ ដល់ចំណែក ហើយនឹងបួស ។*

*ចប់ កោសិយជាតក ៕*

*( សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសកនិបាត បិដកលេខ ៥៩ ទំព័រ ២៥៣ និងអដ្ឋកថា)*

*ដោយស.ដ.វ.ថ.*